**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ចាម**
សំណុំរឿងព្រហ្មទណ្ឌលេខ:៣៥៤
ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២
សាលក្រមលេខ: ៣៣ "ង"
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជាសាធារណៈ នៅសាលាជំនុំជម្រះក្តីនៃសាលាដំបូងខេត្តកំពង់ចាម នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៨:៣០ នាទីព្រឹក។

**ចៅក្រមជំនុំជម្រះ**

**លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម**

**តំណាងអយ្យការ**

**លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម**

**ក្រឡាបញ្ជីសវនាការ**

**លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម**

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៥៤ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ:

១-ឈ្មោះ[redacted]សុខលី ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរ បើកឡានដឹកដី កើតនៅភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្តាល។ជានីតិជន ប្រពន្ធឈ្មោះ [redacted]ម៉ានី មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] ស៊ីម (ស្លាប់) ម្តាយឈ្មោះ[redacted] គឹមហួ (ស្លាប់) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ មានដីកាសម្រេចមិនឃុំខ្លួនលេខ: ៤៦៨ "ដ" ព្រ.ទ/២២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

២-ឈ្មោះ[redacted]ម៉ានី ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ដឹកដីលក់ កើតថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩១ នៅ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្តាល។ជានីតិជន ប្តីឈ្មោះ[redacted]សុខលី មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted]ចំរើន (រស់) ម្តាយឈ្មោះ[redacted]សុខលាប (រស់) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ មានដីកាសម្រេចមិនឃុំខ្លួនលេខ: ៤៦៩ "ដ" ព្រ.ទ/២២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

ជាប់ចោទពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុខលី និងឈ្មោះ[redacted] ម៉ានី ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស្រី ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។

Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៧និង៣០នាទីនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រៃកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមមានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ មួយកើតឡើង បង្កដោយជនសង្ស័យពីនាក់ប្ដីប្រពន្ធ ទី១ឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ៣៥ឆ្នាំ ជាប្ដីបានធ្វើសកម្មភាពចាប់ឈ្មោះ [redacted] ស្រី អាយុ៣០ ហើយស្របពេលនោះឈ្មោះ [redacted] ម៉ានី ភេទស្រី អាយុ៣១ឆ្នាំ ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សុខលី បានយកមែកឈើ មានបន្លាវាយទៅលើឈ្មោះ [redacted] ស្រី អាយុ៣០ឆ្នាំ បណ្ដាលឲ្យរងរបួសច្រើនកន្លែង។បន្ទាប់មក សមត្ថកិច្ចបានចងក្រងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ដើម្បីចាត់ការបន្តតាមច្បាប់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ: ៣៣៩ ព.ស.ខ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៥៩៧ អ.យ.ច/២២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម។

-បានឃើញដីកាដំណោះស្រាយលេខ: ២២៥៩ ៉ដ។ព្រ.ទ/២២ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៦៨៦ ចត ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម។

### នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខលី បានឆ្លើយថា: ខ្ញុំបាទមិនបានប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ចំពោះអង្គហេតុដែលចោទប្រកាន់មកលើខ្ញុំបាទ ខ្ញុំបាទមិនទទួលស្គាល់ទេ។ខ្ញុំបាទមិនបានវាយទៅលើឈ្មោះ [redacted] ស្រី ភេទស្រី អាយុ៣០ឆ្នាំ នឹងដំបង ឬរំពាត់នោះទេតើពេលឈ្មោះ [redacted] ស្រី និងប្រពន្ធខ្ញុំ ប្រតាយប្រតប់គ្នាដោយដៃនឹងដៃនោះ ខ្ញុំបានចូលទៅឃាត់ចាប់ទាញបំបែកតែប៉ុណ្ណោះ មិនបានចូលរួមវាយនោះទេ ព្រោះភាគីម្ខាងទៀតក៏ជាអ្នកដែលខ្ញុំស្គាល់ដែរ។នៅថ្ងៃកើតហេតុថ្ងៃ ខែ ឆ្នាំ មិនចាំ វេលាម៉ោងប្រហែល៥រសៀល ឈ្មោះ [redacted] ស្រី ជិះម៉ូតូឌុបមករកខ្ញុំនៅកន្លែងធ្វើការដឹកដីនៅចំណុចអូរលាក់កូន ហើយក៏បានឈ្លោះប្រកែកជាមួយប្រពន្ធខ្ញុំ ដោយឈ្មោះ [redacted] ស្រី បានស្ទុះចាប់បោចសក់ប្រពន្ធខ្ញុំ ក៏មានការប្រតាយប្រតបគ្នា ខ្ញុំចូលទៅឃាត់បំបែកគ្នាតែឃាត់មិនឈ្នះអ្នកទាំងពីរក៏ប្រតាយប្រតបគ្នារុញគ្នាបណ្ដាលឲ្យឈ្មោះ [redacted] ស្រី ដួលអុកគូទទៅលើព្រៃចិញ្ចើមផ្លូវខ្ទងទប់ ពេលនោះខ្ញុំបាទក៏ដួលដែរ បណ្ដាលឲ្យមានរហូសស្នាមនិងជ្រោងសំរ៉ាស់គេដាំបន្លែ មិនមែនបណ្ដាលមកពីខ្ញុំបាទឬប្រពន្ធខ្ញុំបាទយកដំបងឬរំពាត់ដែលមានបន្លាវាយទៅលើគាត់នោះទេ។ពេលប្រពន្ធខ្ញុំនិងឈ្មោះ [redacted] ស្រី កំពុងប្រតាយប្រតបគ្នានោះ ខ្ញុំបាទកំពុងតែបើកឡានដឹកដីពេលឃើញឈ្លោះគ្នាក៏ចុះពីឡានមកឃាត់ និងចាប់បំបែកគ្នាមនិមែនមកជួយវាយនោះទេ។រឿងហេតុដែលកើតឡើងនេះបណ្ដាលមកពីឈ្មោះ [redacted] ស្រី ពាក់ព័ន្ធស្នេហាជាមួយខ្ញុំបាទហើយគាត់ថាកូនគាត់ជាកូនរបស់ខ្ញុំ ខ្ញុំមិនដឹងថាកូនរបស់ខ្ញុំឬក៏មិនមែនទេ ព្រោះគាត់ជានារីខារ៉ាអូខេ ខ្ញុំបានជួបគាត់ម្ដងៗពេលខ្ញុំទៅច្រៀង ក្រោយមកគាត់តាមរករឿងខ្ញុំនៅកន្លែងធ្វើការរហូត ទើបមានទំនាស់គ្នាជាមួយប្រពន្ធខ្ញុំកើតឡើងនេះ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ានី បានឆ្លើយថា:នាងខ្ញុំមិនបានវាយទៅលើឈ្មោះ [redacted] ស្រី ភេទស្រី អាយុ៣០ឆ្នាំ នឹងដំបង ឬរំពាត់នោះទេ គឺគ្រាន់តែបានប្រតាយប្រតប់គ្នាដៃនឹង

ដៃតែប៉ុណ្ណោះ។នៅថ្ងៃកើតហេតុថ្ងៃ ខែមិនចាំឆ្នាំ២០២២ វេលាប្រហែលម៉ោង១ម៉ោង២រសៀល ឈ្មោះ [redacted]ស្រី ជិះផាស់អាប់ មកកន្លែងនាងខ្ញុំធ្វើការនៅចំណុចអូរលាក់កូនហើយស្រែកប្រាប់នាងខ្ញុំថា ងែងឲ្យប្ដីឯងមកជួបអញ នាងខ្ញុំឆ្លើយថា ទៅប៉ុស្តិ៍តែម្ដងទៅ ចង់រកអ្នកណារកអ្នកនឹងទៅ មិនបាច់មកអុកឡុកនៅកន្លែងអញធ្វើការទេ ហើយឈ្មោះ[redacted]ស្រី ក៏ចុះពីលើផាសអាប់ដើរសំដៅមករកនាងខ្ញុំដោយមានកាន់កូនកាំបិតជៀក្កាមួយ នាងខ្ញុំក៏ស្រែកឲ្យគេជួយ គាត់ក៏ថយទៅវិញ ខ្ញុំស្រែកថាបើចង់ជួបគ្នាទៅជួបនៅកន្លែងប៉ូលីសតែម្ដងទៅ គាត់ក៏ទៅវិញបានប្រហែល២០នាទីនាងខ្ញុំក៏ជិះឡានដឹកដីជាមួយកម្មករទៅតាមក្រោយ ទៅដល់ភូមិត្រង់មាត់ផ្លូវចូលស្រាប់តែឃើញឈ្មោះ[redacted]ស្រី កំពុងនិយាយបរិហាកេរ្តិ៍និងជេរនាងខ្ញុំប្រាប់អ្នកភូមិ។លុះដល់ម៉ោងបីម៉ោងបួន ឈ្មោះ[redacted]ស្រី បានជិះម៉ូតូឌុបទៅកន្លែងនាងខ្ញុំដឹកដីម្ដងទៀតដោយមានយកក្មេងស្រីម្នាក់ទៅជាមួយពេលទៅដល់ស្រែកហៅខ្ញុំឲ្យមកជួប នាងខ្ញុំថាចង់ជួបអ្នកណាទៅរកអ្នកនោះទៅ មិនបាច់មករកអញទេ អាញមិនដឹងរឿងអីទេ ស្រាប់តែឈ្មោះ[redacted]ស្រី ស្ទុះហោមករកនាងខ្ញុំ ខ្ញុំក៏រើសយកដំបងឈើដើមអូយយ៉ះតូចជាងកដៃមកកាន់ហ្នឹងដៃដើម្បីគំរាមកុំឲ្យគាត់ចូលមករកនាងខ្ញុំ បានបន្តិចនាងខ្ញុំក៏បោះដំបងនោះចោលវិញ ហើយឈ្មោះ[redacted]ស្រី បានស្ទុះចាប់បោចសក់នាងខ្ញុំ ក៏បានប្រតាយប្រតប់គ្នាបណ្ដាលឲ្យគាត់ដួលអុកតូទទៅលើព្រៃចិញ្ចើមផ្លូវបណ្ដាលឲ្យមានរបួសស្នាមមិនមែននាងខ្ញុំយកដំបងឬរំពាត់វាយទៅលើគាត់ទេ។ពេលនាងខ្ញុំនិងឈ្មោះ [redacted] ស្រី កំពុងប្រតាយប្រតប់គ្នានោះមានប្ដីនាងខ្ញុំឈ្មោះ ងី សុខលី អ្នករត់ម៉ូតូមិនស្គាល់ឈ្មោះនិងអ្នកភូមិពីរនាក់ មិនស្គាល់ឈ្មោះជួយឃាត់ចាប់បំបែកគ្នា។ចំណែកប្ដីនាងខ្ញុំពុំបានវាយទៅលើឈ្មោះ[redacted]ស្រី ទេបានតែឃាត់កុំឲ្យឈ្លោះគ្នាប៉ុណ្ណោះ។រឿងហេតុដែលកើតឡើងនេះបណ្ដាលមកពីឈ្មោះ [redacted] ស្រី ពាក់ព័ន្ធស្នេហាជាមួយប្ដីនាងខ្ញុំតែពេលនោះនាងខ្ញុំអត់បានដឹងទេ ដឹងតែថាគាត់ថាប្ដីនាងខ្ញុំជំពាក់លុយចំនួន៤,០០០$ តែប្ដីនាងខ្ញុំថាអត់មានជំពាក់ទេ។

-តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រី នៅជំណាក់កាលអយ្យការបានឆ្លើយថា: កន្លងមកនាងខ្ញុំនិងឈ្មោះ[redacted]សុខលី ធ្លាប់ទំនាក់ទំនងស្រឡាញ់គ្នារហូតបានកូន០១ទើបនាងខ្ញុំដឹងថាឈ្មោះ [redacted]សុខលី មានប្រពន្ធរួចហើយ។នាងខ្ញុំនិងឈ្មោះ[redacted] សុខលី មិនបានរៀបការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាទេ។ ក្រោយមកគាត់បានធ្វើកិច្ចសន្យាបង់លុយចិញ្ចឹមកូន១ខែ ៣០០$(បីរយដុល្លាអាមេរិក)។ឈ្មោះ [redacted] សុខលី ធ្លាប់បានឲ្យនាងខ្ញុំខ្ចីលុយគេចំនួន៤,៥០០$(បួនពាន់ប្រាំរយដុល្លាអាមេរិក)ដើម្បីទៅសងថ្លៃប្រេងហើយលុយនេះគាត់មិនទាន់បានសងមកនាងខ្ញុំវិញ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១៤និ០០នាទី នាងខ្ញុំបានជិះផាសអាប់ ទៅការដ្ឋានគ្រឿងចក្ររបស់ឈ្មោះ[redacted]សុខលី ស្ថិតនៅក្រោយសាលាតាពុំ ភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទៅដល់កន្លែងនោះដំបូងនាងខ្ញុំហៅឈ្មោះ[redacted]សុខលី គាត់មិនព្រមចេញមកទេ នាងខ្ញុំបានជិះផាសអាប់ចេញមកវិញមួយសន្ទុះក្រោយមកនាងខ្ញុំចុចទូរស័ព្ទហៅគាត់ម្ដងទៀត តែគេពុំចូល នាងខ្ញុំក៏សម្រេចចិត្តជិះម៉ូតូឌុបចូលទៅទីនោះម្ដងទៀត ហើយស្រែកហៅឈ្មោះ[redacted] សុខលី ឲ្យជួយដោះស្រាយលុយដែលឲ្យនាងខ្ញុំខ្ចីគេ ភ្លាមនោះឈ្មោះ[redacted] សុខលី បានចេញមកចាប់បោចសក់នាងខ្ញុំទាញទៅក្រោយឲ្យឈប់ រួចនាងខ្ញុំនិងឈ្មោះ[redacted]សុខលី បានប្រតាយប្រតប់គ្នា ហើយពេលនោះឈ្មោះ ជាប ម៉ានី ប្រពន្ធគាត់ចេញមកយកប្រនង់មែកឈើមានបន្លា ប្រវែងប្រហែល២ម៉ែត្រ មកវាយនាងខ្ញុំដោយកូនចៅប្រុសពីរនាក់ទៀតមកចាប់នាងខ្ញុំ។ឈ្មោះ[redacted]ម៉ានី បានវាយនាងខ្ញុំនិងប្រនង់ត្រូវចំស្មងជើងខាងឆ្វេងមួយ ត្រូវចំចង្កេះ ត្រូវក្បាល ខ្នង និងដៃ បណ្ដាលឲ្យមានស្នាមរបួស។ក្នុងរឿងនេះនាងខ្ញុំសុំឲ្យតុលាការផ្ដន្ទាទោសជនល្មើសតាមច្បាប់ ទាមទារប្រាក់ដែលឈ្មោះ[redacted]សុខលី ឲ្យនាងខ្ញុំខ្ចីគេចំនួន៤,៥០០$ (បួនពាន់ប្រាំរយ

ដុល្លាអាមេរិក) និងទាមទារជំងឺចិត្តចំនួន៥,០០០$(ប្រាំពាន់ដុល្លាអាមេរិក)។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រឿន នៅដំណាក់កាលសមត្ថកិច្ច បានឆ្លើយថា: កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៦និង៥០នាទី ខ្ញុំបាទបានឌុបនារីម្នាក់និងកូនស្រីម្នាក់អាយុប្រហែល៣ឆ្នាំ ទៅរកឈ្មោះ [redacted] សុខលី នៅមុំសាលាឆទានតាពុំ ភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។នៅពេលទៅដល់ឈ្មោះ [redacted] ស្រី បានស្រែកហៅឈ្មោះ [redacted] សុខលី ពីចំងាយភ្លាមនោះឈ្មោះ [redacted] សុខលី បានដើរចេញមកជាមួយប្រពន្ធគាត់ នៅពេលបានជួបគ្នាអ្នកទាំងបីបានឈ្លោះប្រកែកគ្នាជេរទៅជេរមក បានបន្តិចក្រោយមកឈ្មោះ [redacted] ស្រី និងប្រពន្ធរបស់ ធី សុខលី ដែលមានឈ្មោះ [redacted] ម៉ានី ឈ្លោះគ្នាឈានរហូតដល់មានការប្រតាយប្រតប់គ្នាហើយឈ្មោះ ជាប ម៉ានី ទាញបានដំបងឈើទំហំប៉ុនកដៃប្រវែងប្រហែល១,៥០ម៉ែត្រ វាយទៅលើឈ្មោះ [redacted] ស្រី ឈ្មោះ [redacted] ស្រី រត់គេចពួនពីក្រោយខ្នងខ្ញុំ ឈ្មោះ [redacted] ម៉ានី នៅតែបន្តវាយត្រូវខ្លះខុសខ្លះ ពេលនោះឈ្មោះ [redacted] សុខលី និងរូបខ្ញុំបាទនាំគ្នាឃាត់បំបែករួចខ្ញុំក៏ឌុបឈ្មោះ [redacted] ស្រី និងកូនស្រីមកផ្សារព្រែកដំបូកវិញ ខ្ញុំបានលុយមួយម៉ឺនរៀលហើយក៏ជិះម៉ូតូចេញទៅផ្ទះខ្ញុំបាត់ទៅ។

**-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា:** ក្រោយពីបញ្ចប់ការសួរដេញដោល និងពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ នៅចំណុចភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ពិតជាមានករណី **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ម៉ានី បានយករំពាត់វាយទៅលើជនរងគ្រោះប្រាកដមែន គឺបំពេញនូវគ្រប់ធាតុផ្សំនៃបទល្មើស និងមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសារភាពរបស់ដើមបណ្ដឹង និងភស្តុតាងដែលមាននៅក្នុងសំណុំរឿង អំពើដែលជនជាប់ចោទប្រព្រឹត្តបានបង្កឲ្យមានរបួសដល់អ្នកដទៃ និងប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈសន្តិសុខសង្គម ។ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សុខលី តំណាងអយ្យការយល់ឃើញថាជននេះមិនបានចូលរួមប្រព្រឹត្តអំពើហិង្សាទៅលើឈ្មោះ [redacted] ស្រី នោះទេ ដោយពុំមានអត្ថិភាពនៃបទល្មើស និងពុំមានធាតុផ្សំគ្រប់គ្រាន់ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ។ដូច្នេះតំណាងអយ្យការស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់លើឈ្មោះ [redacted] សុខលី និងស្នើសុំឲ្យផ្ដន្ទាទោសលើឈ្មោះ [redacted] ម៉ានី ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ**។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] ម៉ានី បានធ្វើសេចក្ដីសន្និដ្ឋានការពារថា:កូនក្ដីរបស់ខ្ញុំបាទឈ្មោះ [redacted] សុខលី គឺពុំបានធ្វើសកម្មភាពវាយទៅលើឈ្មោះ [redacted] ស្រី នោះទេ គឺទៅជួយឃាត់ឈ្មោះ [redacted] ស្រី កុំឲ្យប្រតាយប្រតប់គ្នាជាមួយនឹងប្រពន្ធរបស់ខ្លួនតែប៉ុណ្ណោះ ហើយតាមចម្លើយរបស់ឈ្មោះ [redacted] ម៉ានី ប្ដីរបស់ខ្លួនពុំបានវាយទៅលើឈ្មោះ [redacted] ស្រី ទេ ចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] រឿន បានបញ្ជាក់ថាឈ្មោះ [redacted] ស្រី បានប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] ម៉ានី តែប៉ុណ្ណោះ តែឈ្មោះ [redacted] សុខលី ពុំបានចូលរួមប្រព្រឹត្តអំពើហិង្សានោះទេ។ចំពោះកូនក្ដីខ្ញុំឈ្មោះ [redacted] ម៉ានី គឺពិតជាបានវាយគ្នាទៅវិញទៅមករវាងឈ្មោះ [redacted] ស្រី និងខ្លួនប្រាកដមែនដែលរឿងនេះគឺផ្ដើមចេញពីឈ្មោះ [redacted] ស្រី មុនដែលបានទៅរករឿងខ្លួន និងប្ដី ដល់កន្លែងការដ្ឋានធ្វើការរបស់ខ្លួនព្រមទាំងមានកាន់កូនកាំបិតជៀជ័រនៅនឹងខ្លួនទៀត ចំណែកការប្រើប្រាស់មែកឈើមានបន្លាវាយទៅលើឈ្មោះ [redacted] ស្រី នោះគឺគ្មាននោះទេ។ដោយឡែកចំពោះឈ្មោះ [redacted] ស្រី គឺពុំបានចូលខ្លួនតាមការកោះហៅនិងពុំបានចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ហើយនៅពេលសវនាការក៏ពុំបានចូលខ្លួនមកឆ្លើយបំភ្លឺ ដើម្បីទាមទារសំណងនោះទេ។ផ្នែក

តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងថាវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ផ្អែកតាមរយៈការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំលោកចៅក្រមជំនុំជម្រះ មេត្តាពិនិត្យ ពិចារណា ចេញសាលក្រមចុងក្រោយសម្រេច ប្រកាសឲ្យឈ្មោះ [redacted] សុខលី រួចខ្លួនពីបទចោទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ និងសុំកែប្រែបទចោទលើឈ្មោះ [redacted] ម៉ានី ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ មកបទ ហិង្សាដោយចេតនា និងប្រកាសព្យួរទោសលើឈ្មោះ [redacted] ម៉ានី ដោយក្តីអនុគ្រោះ។

-ជនជាប់ចោទឈ្មោះ [redacted] សុខលី បាននិយាយសំដីចុងក្រោយថាៈ ខ្ញុំបាទសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំបាទផង និងសុំឲ្យតុលាការលើកលែងចោទប្រកាន់ ព្រោះខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ានី បាននិយាយសំដីចុងក្រោយថាៈ ខ្ញុំបាទសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំបាទផង និងសុំឲ្យតុលាការលើកលែងចោទប្រកាន់ ព្រោះខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-ក្រោយពីបានដំណើរការសវនាការ
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង
-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកំពង់ចាម**

**យល់ឃើញថា**

-តាមដីកាដំណោះស្រាយលេខៈ ២២៥០ "ដ"ព្រ.ទ/២២ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ម៉ានី ភេទស្រី អាយុ៣១ឆ្នាំ មកតុលាការជំនុំជម្រះពីបទៈ **ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។តុលាការអាចលើកយកសំណុំរឿងនេះមកជំនុំជម្រះបានតាមមាត្រា២៩១ (របៀបប្តឹងទៅតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ពិតជាមានអង្គហេតុ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដោយជនជាប់ចោទឈ្មោះ ជាប ម៉ានី ពិតប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] សុខលី បានឆ្លើយបដិសេធថាខ្លួនមិនបានយកដំបងឬវាំពាតវាយទៅលើឈ្មោះ [redacted] ស្រី នោះទេ គឺប្រពន្ធរបស់ខ្លួន និងឈ្មោះ [redacted] ស្រី បានប្រតាយប្រតប់គ្នាហើយខ្លួនចូលទៅជួយឃាត់តែប៉ុណ្ណោះ គប្បីតុលាការពិចារណា និងសម្រេច។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ានី បានឆ្លើយបដិសេធថាខ្លួនមិនបានយកដំបងឬរំពាតវាយទៅលើឈ្មោះ [redacted] ស្រី នោះទេ គឺគ្រាប់តែមានការប្រតាយប្រតប់គ្នាហើយឈ្មោះ [redacted] ស្រី បានដួលអុកគូទទៅលើព្រៃ បណ្តាលឲ្យមានរបួស គប្បីតុលាការពិចារណា និងសម្រេច។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,តាមចម្លើយរបស់សាក្សី និងតាមការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង គឺអាចបញ្ជាក់បានថានៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] ម៉ានី ពិតជាបានប្រព្រឹត្តនូវបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ ពិតប្រាកដមែន គប្បីតុលាការពិចារណា និងសម្រេច។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ានី ធ្វើឲ្យមានរបួសដល់អ្នកដទៃ និងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមដែលច្បាប់បានបញ្ញត្តិថាអំពើនេះជាបទល្មើសហិង្សាដោយចេតនា មានស្ថានទម្ងន់ទោសដោយប្រើអាវុធ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ានី ជានីតិជនដែលមានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តនិងអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ានី ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ។

ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

-ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សុខលី បានឆ្លើយបដិសេធថាខ្លួនមិនបានយកដំបងឬរំពាតវាយទៅលើឈ្មោះ [redacted] ស្រី នោះទេ គឺប្រពន្ធរបស់ខ្លួន និងឈ្មោះ [redacted] ស្រី បានប្រតាយប្រតប់គ្នាហើយខ្លួនចូលទៅជួយឃាត់តែប៉ុណ្ណោះ ដោយចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] រឿន ដែលបានបញ្ជាក់ថាឈ្មោះ [redacted] សុខលី បាននិងរូបខ្លួនបានចូលទៅឃាត់ឈ្មោះ [redacted] ស្រី និងឈ្មោះ [redacted] ម៉ានី កុំឲ្យវាយគ្នាពិតមែន គប្បីតុលាការពិចារណា និងសម្រេចឲ្យរួចផុតបទចោទប្រកាន់។

-គ្មានភស្តុតាង និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ។

ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

-វត្ថុតាងមាន:ដំបងឈើមូលចំនួន០១កំណាត់ និងជ័រពណ៌ខ្មៅចំនួន០២បំណែក គប្បីសម្រេចរឹបអូសបំផ្លាញចោល។

-ដើមបណ្តឹងឈ្មោះ [redacted] ស្រី បានទាមទារប្រាក់ដែលឈ្មោះ [redacted] សុខលី បានឲ្យខ្លួនខ្ចីគេចំនួន៨,៥០០ដុល្លាអាមេរិក និងទាមទារជំងឺចិត្តចំនួន៥,០០០ដុល្លាអាមេរិក គប្បីតុលាការពិចារណា និងសម្រេច។

## ហេតុដូច្នេះសាលាដំបូងខេត្តកំពង់ចាម
## វិនិច្ឆ័យសេចក្តី

១-ឲ្យរួចផុតបទចោទលើឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយ

Scanned with CamScanner

សាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ម៉ានី ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា។

ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ** ប្រព្រឹត្តនៅចំណុចក្រោយសាលាឆទានតាពុំ ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម មាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉ានី សងសំណងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ វ៉ា ស្រី ចំនួន ៥,០០០,០០០ (ប្រាំលាន)រៀល ដើមបណ្តឹងទារលើសពីនេះបដិសេធចោល។

៤-វត្ថុតាងមាន:ដំបងឈើមូលចំនួន០១កំណាត់ និងជ័រពណ៌ខ្មៅចំនួន០២បំណែក សម្រេចរឹបអូសបំផ្លាញចោល។

-សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខលី ,ជនជាប់ចោទឈ្មោះ [redacted] ម៉ានី ,មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] ម៉ានី និងកំបាំងមុខដើមបណ្តឹងឈ្មោះ [redacted] ស្រី ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានឃើញ
ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅ កំពង់ចាម ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
**ក្រឡាបញ្ជីសវនាការ**
[redacted]

Scanned with CamScanner